រដ្ឋសភា

# បទបញ្ជាផ្ទៃក្នុង នៃរដ្ឋសភា

# នៃ

# ព្រះរាជាណាចក្រកម្ពុជា

## **ជំពូកទី ១**
## **អំពីការិយាល័យបណ្ដោះអាសន្ន និងការកិច្ច**

**ប្រការ ១** :

*រដ្ឋសភាប្រជុំជាសាមញ្ញពីរដងក្នុង ១ ឆ្នាំ ។*

*សម័យប្រជុំនីមួយៗ មានចិរវេលាយ៉ាងតិចបីខែ ។*

**ប្រការ ២ ថ្មី** (**ពីរ**) :

*នៅពេលបើកសម័យប្រជុំលើកទី១ នៃនីតិកាលនីមួយៗរដ្ឋសភាត្រូវចាប់ដំណើរការក្រោមអធិបតីភាពប្រធានបណ្ដោះអាសន្នមួយរូបដែលជាបេក្ខជនជាប់ឆ្នោតមានអាយុច្រើនជាងគេដែលមានវត្តមាន ហើយមានសមាជិកប្រាំរូប ដែលជាបេក្ខជនជាប់ឆ្នោតមាន អាយុតិចជាងគេដែលមានវត្តមាន ជាលេខាធិការដើម្បីជួយប្រធានក្នុងការងារ ។*

**ក**-*ក្នុងករណីធម្មតា ក្រោមការដឹកនាំរបស់ព្រឹទ្ធសមាជិករដ្ឋសភាខាងលើនេះ ប្រសិនបើមានកូរ៉ុមលើសពីពាក់កណ្ដាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល រដ្ឋសភាត្រូវចាប់ផ្ដើមធ្វើការតាមរបៀបវារៈដូចតទៅ :*

**១**-*សម្រេចអំពីសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ ។*

**២**-*បោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវ ប្រធាន អនុប្រធានទាំងពីររបស់រដ្ឋសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។*

*មិនអាចជជែកពិភាក្សាអ្វីឡើយនៅក្រោមអធិបតីភាពរបស់ព្រឹទ្ធ-*

សមាជិក ។

តំណាងរាស្ត្រទាំងអស់ត្រូវធ្វើសច្ចាប្រណិធានមុនពេលចូលកាន់តំណែងដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៥ នៃរដ្ឋធម្មនុញ្ញ ។

**ខ**-ក្នុងករណីដែលស្ថានភាពនយោបាយតម្រូវឲ្យអនុវត្តតាមច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិក្រោមការដឹកនាំរបស់ព្រឹទ្ធសមាជិករដ្ឋសភាខាងលើនេះ ប្រសិនបើមានកូរ៉ុម លើសពីពាក់កណ្ដាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល រដ្ឋសភាត្រូវចាប់ផ្ដើមធ្វើការតាមរបៀបវារៈដូចតទៅ :

**១**-សម្រេចអំពីសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ ។

**២**-បោះឆ្នោតជាកញ្ចប់ដើម្បីជ្រើសតាំង ប្រធាន អនុប្រធានរដ្ឋសភា ប្រធាន អនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា និងផ្ដល់សេចក្ដីទុកចិត្តចំពោះរាជរដ្ឋាភិបាលនៅដើមនីតិកាលនីមួយៗ ដោយវិធីលើកដៃនិងដោយសំឡេងភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

មិនអាចជជែកពិភាក្សាអ្វីឡើយនៅក្រោមអធិបតីភាពរបស់ព្រឹទ្ធសមាជិក ។

តំណាងរាស្ត្រទាំងអស់ត្រូវធ្វើសច្ចាប្រណិធានមុនពេលចូលកាន់តំណែងដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៥ នៃរដ្ឋធម្មនុញ្ញ ។

## ជំពូកទី ២
## អំពីសុពលភាពនៃអ្នកតំណាងរាស្ត្រ

**ប្រការ ៣ ថ្មី(ពីរ)** :

*នៅពេលបើកសម័យប្រជុំខាងលើនេះ ព្រឹទ្ធសមាជិករដ្ឋសភាប្រកាស ជូនអង្គសភា :*

*-ឈ្មោះបេក្ខជនជាប់ឆ្នោតជាស្ថាពរ ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានបញ្ជូនមក ។*

*-ឈ្មោះបេក្ខជនជាប់ឆ្នោតដែលមានគេប្ដឹងតវ៉ា ហើយដែលក្រុមប្រឹក្សាធម្មនុញ្ញបានបដិសេធបណ្ដឹងទាំងនោះ ។*

*ការប្រកាសសុពលភាពខាងលើនេះ មិនអាចធ្វើបានឡើយក្នុងករណីដែលមានគណបក្សនយោបាយណាមួយទទួលអាសនៈមួយឬច្រើនក្នុងរដ្ឋសភាធ្វើពហិការមិនព្រមចូលរួមសម័យប្រជុំដំបូងតាមការកោះប្រជុំរបស់ព្រះមហាក្សត្រឬធ្វើពហិការមិនព្រមចូលរួមប្រជុំរដ្ឋសភាសម្រាប់ការប្រកាសសុពលភាព នៃអាណត្តិរបស់សមាជិកនីមួយៗ ។*

*ក្នុងករណីនេះព្រឹទ្ធសមាជិករដ្ឋសភាត្រូវចាត់នីតិវិធីតាមបទប្បញ្ញត្តិនៃមាត្រា ១៣៨ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។*

*ឈ្មោះតំណាងរាស្ត្រទាំងអស់ ដែលបានប្រកាសសុពលភាព រួចហើយត្រូវបិទផ្សាយក្នុងរដ្ឋសភា ផ្សព្វផ្សាយជាសាធារណៈ ក្រោយពេលប្រជុំ និងត្រូវចុះផ្សាយក្នុងរាជកិច្ចក្រោយពីបានធ្វើសច្ចាប្រណិធានចូលកាន់តំណែង ។*

**ប្រការ ៤ ថ្មី** :

*តំណាងរាស្ត្រមានឋានៈ និងបុព្វសិទ្ធិស្មើនឹងឧត្តមមន្ត្រីផុតលេខនៃព្រះរាជាណាចក្រកម្ពុជា ។*

*តំណាងរាស្ត្រគ្រប់រូប ត្រូវបានទទួលការធានារ៉ាប់រងសង្គម នៅក្នុងអាណត្តិរបស់ខ្លួន ។ ដោយឡែក ក្នុងករណីដែលតំណាងរាស្ត្រទទួលអនិច្ចកម្មនៅក្នុងអាណត្តិ រដ្ឋសភាត្រូវទទួលបន្ទុករៀបចំពិធីបុណ្យសព និងផ្តល់ប្រាក់បំណាច់ ព្រមទាំងប្រាក់ឧបត្ថម្ភផ្សេងៗ គ្រប់យ៉ាងដល់គ្រួសារសពរយៈពេលមួយឆ្នាំទៀតគិតពីថ្ងៃទទួលអនិច្ចកម្ម ។*

*គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវរៀបចំរបបប្រាក់បំណាច់ របបធានារ៉ាប់រងសង្គម របបបេសកកម្ម និងលក្ខខណ្ឌធ្វើការងារ របស់តំណាងរាស្ត្រ ។*

## ជំពូកទី ៣
## អំពីគណៈកម្មាធិការអចិន្ត្រៃយ៍
## និងគណៈកម្មការនានានៃរដ្ឋសភា

**ប្រការ ៥ ថ្មី (ពីរ)** :

*ក្រោយពីព្រះមហាក្សត្រ ឬព្រះរាជតំណាងបានបើកនីតិកាលរដ្ឋសភារួចហើយ ហើយបើអង្គសភាមានសមាជិកវត្តមានលើសពីពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល រដ្ឋសភាអាចដំណើរការបន្ត តាមរបៀបវារៈដូចមានចែងក្នុងប្រការ ២ ថ្មី (ពីរ) ។*

**ប្រការ ៦ ថ្មី (ពីរ)** :

*គណៈកម្មការនានា នៃរដ្ឋសភាមាន :*

**១**-*គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា*

**២**-*គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម*

**៣**-*គណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក*

**៤**-*គណៈកម្មការមហាផ្ទៃ ការពារជាតិ និង មុខងារសាធារណៈ*

**៥**-*គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន*

**៦**-*គណៈកម្មការនីតិកម្ម និងយុត្តិធម៌*

**៧**-*គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍*

**៨**-*គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាល វិជ្ជាជីវៈ និងកិច្ចការនារី*

**៩**-*គណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់*

**១០**-*គណៈកម្មការអង្កេត បោសសំអាតនិងប្រឆាំងអំពើពុករលួយ*

**ប្រការ ៧ ថ្មី (ពីរ)** :

*គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាមាន* :

*-ប្រធានរដ្ឋសភា*

*-អនុប្រធានទាំងពីរ នៃរដ្ឋសភា*

*-ប្រធានគណៈកម្មការនានា នៃរដ្ឋសភា ។*

*ប្រធានរដ្ឋសភាជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ។*

*កូរ៉ុមសម្រាប់ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវឲ្យមានលើសពីពាក់កណ្តាលនៃចំនួនសមាជិក ។*

*គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាមានអាណត្តិស្មើនឹងនីតិកាលរបស់រដ្ឋសភា ។*

*គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា មានភារកិច្ចដូចតទៅ* :

**ក**-*ដឹកនាំ ចាត់ចែង និងពិនិត្យសម្រេចរាល់ការងារ សកម្មភាពផ្សេងៗរបស់រដ្ឋសភាក្នុងលក្ខខណ្ឌកំណត់នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រមទាំងទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់នូវសេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ*

**ខ**-*ចាត់ចែងការងាររបស់រដ្ឋសភាក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា*

**គ**- *រៀបចំសមាសភាពលេខាធិការបីរូប សម្រាប់សម័យប្រជុំបន្ទាប់ ដើម្បីដាក់ជូនអង្គប្រជុំនៃរដ្ឋសភាអនុម័ត*

**ឃ**-*ដឹកនាំការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា*

**ខ**-ជានាការគ្រប់គ្រង និងការចំណាយថវិការដ្ឋសភាឲ្យប្រព្រឹត្តទៅបានត្រឹមត្រូវតាមការកំណត់ក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

**ច**-ជានាការផ្តល់គ្រឿងឥស្សរិយយសជូនដល់សមាជិករដ្ឋសភា

**ឆ**- ជានាការអនុវត្តវិន័យក្នុងរដ្ឋសភា

**ជ**-លើកជូនរដ្ឋសភា អំពីករណីនៃការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនសមាជិកណាមួយនៃរដ្ឋសភាដោយ អនុវត្តតាមកថាខណ្ឌទី ៣ និងទី ៤ នៃមាត្រា ៨០ នៃរដ្ឋធម្មនុញ្ញ

**ឈ**-លើកជូនរដ្ឋសភាពិនិត្យ និងសម្រេចលើការផ្អាកការឃុំខ្លួន ការចោទប្រកាន់ សមាជិករដ្ឋសភាណាមួយ ដោយសម្លេងបីភាគបួន នៃចំនួនសមាជិករដ្ឋសភាទាំងមូល

**ញ**-លើកជូនរដ្ឋសភាពិនិត្យ និងសម្រេចអំពីការលើកអភ័យឯកសិទ្ធិសភា ការប្រគល់ជូនវិញនូវអភ័យឯកសិទ្ធិសភា ការបោះបង់ចោលការងារ វិសមិតភាព និងការប្រាសចាកសមាជិកភាពរដ្ឋសភា ដោយ សម្លេងពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**ប្រការ ៨ ថ្មី** :

ប្រធានរដ្ឋសភាមានមុខការដូចតទៅនេះ :

**ក**-ជានាការប្រព្រឹត្តទៅនៃរដ្ឋសភាឲ្យបានត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ទទួលអាញ្ញត្តិច្បាប់ និងសេចក្តីសម្រេចចិត្តទាំងឡាយដែលរដ្ឋសភា

*បានអនុម័ត ព្រមទាំងចាត់ចែងការទាក់ទងអន្តរជាតិទាំងឡាយរបស់រដ្ឋសភា*

**ខ**-*ដឹកនាំអង្គប្រជុំនៃរដ្ឋសភានិងគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា*

**គ**-*បើក និងលើកពេលប្រជុំនៃរដ្ឋសភា*

**ឃ**-*ចាត់ចែងការពិភាក្សា ហើយចុះហត្ថលេខាលើកំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា និងការប្រជុំនៃរដ្ឋសភា*

**ង**-*ញ៉ាំងឲ្យប្រតិបត្តិតាមបទបញ្ជាផ្ទៃក្នុង នៃរដ្ឋសភា*

**ច**- *រក្សាការពារសណ្ដាប់ធ្នាប់ក្នុងរដ្ឋសភា*

**ឆ**-*តំណាងរដ្ឋសភាក្នុងការទាក់ទងជាមួយព្រះមហាក្សត្រ និងអាជ្ញាធរសាធារណៈ ។*

**ប្រការ ៩ ថ្មី** :

*អនុប្រធានទាំងពីរជួយធ្វើការប្រធានទៅតាមការបែងចែកភារកិច្ចពីប្រធាន ។ កាលបើប្រធានអវត្តមានឬមកធ្វើការពុំបានអនុប្រធានធ្វើការជួសប្រធានក្នុងឋានៈជាប្រធានស្ដីទីតាមរយៈលិខិតផ្ទេរសិទ្ធិ ។*

**ប្រការ ១០ ថ្មី** (**បី**) :

*ក្នុងករណីធម្មតា រដ្ឋសភាត្រូវបោះឆ្នោតជ្រើសតាំងដាច់ដោយឡែក ពីគ្នានូវសមាជិកគណៈកម្មការនានានៃរដ្ឋសភា ។*

*គណៈកម្មការនីមួយៗត្រូវជ្រើសតាំង ប្រធានមួយរូប អនុប្រធាន*

មួយរូបនិងលេខាធិការ មួយរូបដោយវិធីបោះឆ្នោត ។

ក្នុងករណីដែលស្ថានភាពនយោបាយតម្រូវឲ្យអនុវត្តតាមច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ ការជ្រើសរើសប្រធាន និងអនុប្រធានគណៈកម្មការនានា នៃរដ្ឋសភាត្រូវអនុវត្តតាមចំណុច ខ.២ នៃប្រការ ២ ថ្មី (ពីរ) ។ បន្ទាប់មករដ្ឋសភាអាចដំណើរការបន្តដើម្បីជ្រើសតាំងដាច់ដោយឡែកពីគ្នានូវសមាជិកគណៈ-កម្មការនានា នៃរដ្ឋសភាដោយសំឡេងភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ពេលប្រធានគណៈកម្មការអវត្តមាន អនុប្រធានគណៈកម្មការបំពេញការងារជួសប្រធានក្នុងឋានៈជាប្រធានស្ដីទី តាមរយៈលិខិតផ្ទេរសិទ្ធិ ។

កូរ៉ុមសម្រាប់ប្រជុំគណៈកម្មការនានា ត្រូវឲ្យមានលើសពីពាក់កណ្ដាលនៃចំនួនសមាជិក ។

គណៈកម្មការនីមួយៗ មានសមាជិកយ៉ាងតិចប្រាំពីររូប ។

តំណាងរាស្ត្រមួយរូប អាចជាសមាជិកពីរគណៈកម្មការបាន ។

សមាជិកគណៈកម្មការចំនួន ៣ (បី) រូបយ៉ាងតិច អាចស្នើសុំប្រជុំគណៈកម្មការ ។ សំណើនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយមានបញ្ជាក់ពីមូលហេតុសមស្រប ។ ប្រធានគណៈកម្មការអាចកោះប្រជុំគណៈកម្មការតាមសំណើខាងលើនេះបាន ។

**ប្រការ ១១** :

*រដ្ឋសភាអាចតាំងគណៈកម្មការពិសេសដែលមានសមាជិកច្រើន ឬតិចតាមតម្រូវការ ។*

**ប្រការ ១២** :

*គណៈកម្មការនីមួយៗ អាចស្នើសុំប្រធានរដ្ឋសភាចាត់តាំងអ្នកជំនាញដែលមិនមែនជាអ្នកតំណាងរាស្ត្រឲ្យចូលរួមធ្វើការបាន ។ អ្នកជំនាញនោះគ្មានសិទ្ធិសម្រេចក្នុងគណៈកម្មការទេ ។*

**ប្រការ ១៣** :

*សមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មការនានារបស់រដ្ឋសភាដែលខានមកប្រជុំដោយឥតជូនដំណឹងត្រូវទទួលទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងប្រការ ៦៨ ៦៩ ៧០ ៧១ និង៧២ ។*

## ជំពូកទី ៤
## អំពីអគ្គលេខាធិការដ្ឋាន

**ប្រការ ១៤ ថ្មី** (**ពីរ**) :

*រដ្ឋសភាមានអគ្គលេខាធិការដ្ឋានមួយ ដែលមានតួនាទី និងភារកិច្ចដូចខាងក្រោម :*

**ក**-*រៀបចំធ្វើកំណត់ហេតុរបស់រដ្ឋសភា*

**ខ**-*ទទួលបន្ទុករង់នូវគ្រប់កិច្ចការរដ្ឋបាលនិងសេវានានាជូនរដ្ឋសភា*

**គ**-ទំនាក់ទំនងផ្សេងៗ ក្រៅរដ្ឋសភា

**ឃ**-ទទួលរ៉ាប់រងសន្តិសុខ និងសណ្តាប់ធ្នាប់នៅក្នុងរដ្ឋសភា

**ង**-ទទួលការកិច្ចផ្សេងៗដែលប្រធានរដ្ឋសភាប្រគល់ឲ្យ

**ច**-អនុវត្តតួនាទីនិងភារកិច្ចដែលមានកំណត់នៅក្នុងសេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ។

**ប្រការ ១៥ ថ្មី (ពីរ)** :

អគ្គលេខាធិការដ្ឋាន ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប និងអមដោយអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ ។

អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវជ្រើសតាំងក្នុងចំណោមមន្ត្រីជាន់ខ្ពស់ មានបទពិសោធន៍ក្នុងកិច្ចការរដ្ឋបាល យ៉ាងតិចដប់ឆ្នាំ ហើយដែលមិនមែនជាសមាជិករដ្ឋសភា និងមិនមែនជាអ្នកដឹកនាំ ក្នុងគណបក្សនយោបាយណាមួយ ។

**ប្រការ ១៦** :

អគ្គលេខាធិការ និងអគ្គលេខាធិការរងត្រូវតែងតាំង ដោយព្រះរាជក្រឹត្យ តាមសេចក្តីស្នើរបស់ប្រធានរដ្ឋសភាក្រោយពីបានពិគ្រោះជាមួយអនុប្រធានទី១ និងអនុប្រធានទី២ នៃរដ្ឋសភា ។

អគ្គលេខាធិការនិងអគ្គលេខាធិការរងមានឋានៈស្មើនឹងរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ ។

**ប្រការ ១៧ ថ្មី** :

*បុគ្គលិកទាំងអស់នៃអគ្គលេខាធិការដ្ឋានត្រូវតែងតាំងដោយប្រធានរដ្ឋសភាស្របតាមច្បាប់ស្ដីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិ-ប្បញ្ញត្តិ ។*

**ប្រការ ១៨ ថ្មី** :

*កំណត់ហេតុទាំងអស់ និងឯកសារដទៃទៀតរបស់រដ្ឋសភា ត្រូវរក្សាទុកនៅក្នុងអគ្គលេខាធិការដ្ឋានរដ្ឋសភា ។ អគ្គលេខាធិការរដ្ឋសភាអាចផ្ដល់ជូនសាធារណជន និងតំណាងរាស្ត្រនូវកំណត់ហេតុ និងឯកសារខាងលើតាមការស្នើសុំ លើកលែងតែកំណត់ហេតុ និងឯកសារសម្ងាត់ដែលត្រូវមានការអនុញ្ញាតពីប្រធានរដ្ឋសភា ។*

## ជំពូកទី ៥
## អំពីរបៀបវារៈ

**ប្រការ ១៩** :

*គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាជាអ្នករៀបចំរបៀបវារៈនៃពេលប្រជុំនីមួយៗ ។ មុនផុតពេលប្រជុំនីមួយៗ ប្រធានអានរបៀបវារៈសម្រាប់ពេលប្រជុំបន្តទៅទៀត ។*

**ប្រការ ២០ ថ្មី** :

*ក្នុងរបៀបវារៈ មានសេចក្ដីជាលំដាប់មុនក្រោយដូចតទៅនេះ :*

*១-បញ្ហាទាំងឡាយ ដែលរដ្ឋសភាបានសម្រេចថាទុកជាការប្រញាប់*

*២-បញ្ហាទាំងឡាយ ដែលរាជរដ្ឋាភិបាលជូនមករដ្ឋសភា*

*៣-បញ្ហាទាំងឡាយ ដែលគណៈកម្មការនានាជូនមករដ្ឋសភា*

*៤-បញ្ហាទាំងឡាយ ដែលសមាជិករដ្ឋសភាជូនមករដ្ឋសភា ។*

*បើក្នុងប្រភេទនីមួយៗមានបញ្ហាជាច្រើននោះរបៀបវារៈនៃបញ្ហាទាំងនោះ ត្រូវរៀបចំតាមលំដាប់កាលបរិច្ឆេទនៃការបញ្ជូនមកដល់ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា លើកលែងតែមានការសម្រេចផ្សេងពីនេះ ។*

## ជំពូកទី ៦
## អំពីសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់

**ប្រការ ២១ ថ្មី** :

*សេចក្តីព្រាងច្បាប់របស់រាជរដ្ឋាភិបាល ត្រូវបញ្ជូនមកគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ។ សេចក្តីព្រាងច្បាប់នោះធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវចែកជូនតំណាងរាស្ត្រទាំងអស់ព្រមទាំងសេចក្តីថ្លែងហេតុមកជាមួយផង ។*

*គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាបញ្ជូនសេចក្តីព្រាងនោះទៅគណៈកម្មការតាមមុខជំនាញឲ្យពិនិត្យ ។ កាលបើពិនិត្យរួចហើយប្រធាននៃគណៈកម្មការនោះត្រូវនាំយកយោបល់គណៈកម្មការមកជម្រាបជូនរដ្ឋសភា ។*

**ប្រការ ២២ ថ្មី (ពីរ)** :

*សេចក្តីស្នើច្បាប់ដែលតំណាងរាស្ត្រ ឬសមាជិកព្រឹទ្ធសភាជាអ្នកធ្វើនោះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ចែកជាមាត្រា ហើយមានសេចក្តីថ្លែងហេតុនៅខាងដើមជាប់មកជាមួយផង ។*

*គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាបញ្ជូនសេចក្តីស្នើនោះទៅគណៈកម្មការតាមមុខជំនាញឲ្យពិនិត្យ ។ កាលបើពិនិត្យរួចហើយប្រធាននៃគណៈកម្មការនោះត្រូវនាំយកយោបល់របស់គណៈកម្មការមកជម្រាបជូនរដ្ឋសភា ។*

**ប្រការ ២៣** :

*អ្នកតែងសេចក្តីស្នើច្បាប់មានសិទ្ធិចូលរាយការណ៍ជម្រាបគណៈកម្មការដែលពិនិត្យសេចក្តីស្នើនោះ ។*

**ប្រការ ២៤** :

*គណៈកម្មការអាចសន្និដ្ឋានថា* :

*-សូមឲ្យរដ្ឋសភាលើកចោលពុំពិចារណាក៏បាន ។*

*-សូមឲ្យរដ្ឋសភាបញ្ចេញមតិជាមុនសិន តើគួរទទួលពិចារណាឬទេ ។*

*-សូមឲ្យរដ្ឋសភាទទួលពិចារណា ហើយនិងទុកជាការប្រញាប់ផងក៏បាន ។*

**ប្រការ ២៥** :

*អ្នកតែងសេចក្តីស្នើច្បាប់អាចដកសេចក្តីស្នើនោះចេញបានទោះបីរដ្ឋសភាចាប់ពិភាក្សាហើយក៏ដោយ ។ សេចក្តីស្នើច្បាប់ដែលដកចេញនោះ សមាជិកឯទៀតអាចសុំឲ្យរដ្ឋសភាពិភាក្សាវិញបាន ។*

## ជំពូកទី ៧
## អំពីការពិភាក្សាលើសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់

**ប្រការ ២៦** :

*អ្នកតំណាងរាស្ត្រគ្រប់រូបអាចស្នើសុំធ្វើវិសោធនកម្មលើសេចក្តី-ព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់បាន ។ ពាក្យសុំធ្វើវិសោធនកម្មនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរជូនទៅគណៈកម្មការជំនាញក៏បាន ឬជូនទៅរដ្ឋសភាក្នុងពេលប្រជុំពេញអង្គក៏បាន ។*

**ប្រការ ២៧** :

*អង្គសភាសម្រេចថាយល់ព្រម ឬមិនយល់ព្រមយកពាក្យសុំនោះមកពិភាក្សា ។*

**ប្រការ ២៨** :

*អង្គសភាមិនអនុម័តលើវិសោធនកម្មក្នុងថ្ងៃដែលទទួលពាក្យសុំនោះទេ វៀរលែងតែជាការប្រញាប់ ។*

**ប្រការ ២៩** (ថ្មី) :

*ការពិភាក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ត្រូវធ្វើដូចតទៅ :*

**១**-*អង្គសភាពិភាក្សា និងអនុម័តលើខ្លឹមសារទាំងមូល គឺបញ្ចេញមតិថាតើគួរទទួលពិចារណា ឬទេ ។*

**២**-*អង្គសភាពិភាក្សា និងអនុម័តលើមាត្រាមួយម្តងៗក៏បាន ឬលើជំពូកមួយម្តងៗក៏បាន ។*

*អង្គសភាអាចប្រើនីតិវិធីពិភាក្សាសង្ខេបបាន ដោយពិភាក្សាតែមាត្រាឬជំពូកណាដែលមានសំណើធ្វើវិសោធនកម្មជាលាយលក្ខណ៍អក្សរដូចមានចែងក្នុងប្រការទាំងឡាយខាងលើនេះ ។*

*ក្នុងករណីដែលនឹងត្រូវប្រើនីតិវិធីណាមួយខាងលើនេះ គណៈកម្មាធិការអចិន្ត្រៃយ៍ ត្រូវជូនព័ត៌មានដល់អ្នកតំណាងរាស្ត្រជាមុន ។*

**៣**-*អង្គសភាអនុម័តលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ទាំងមូល ។*

## ជំពូកទី ៨
## អំពីបញ្ញត្តពិសេសសម្រាប់ថវិកាជាតិ និងថវិកាសម្រាប់រដ្ឋសភា

**ប្រការ ៣០** :

*សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុត្រូវញែក និងបំបែកជាលំអិតឲ្យបានច្បាស់លាស់តាមការកំណត់ក្នុងច្បាប់ស្តីពីរបបគ្រប់គ្រងរូបិយវត្ថុ និង*

ប្រព័ន្ធហិរញ្ញវត្ថុ ដែលមានចែងក្នុងមាត្រា ៥៧ នៃរដ្ឋធម្មនុញ្ញ ។

**ប្រការ ៣១ ថ្មី (បី)** :

រដ្ឋសភាមានថវិកាស្វយ័តសម្រាប់ដំណើរការ ។ គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ដោយមានការចូលរួមពីតំណាងគណៈកម្មការនានារបស់រដ្ឋសភាមានភារកិច្ចពិនិត្យ និងលើកយោបល់ក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋសភា ដែលរៀបចំដោយអគ្គលេខាធិការដ្ឋានរដ្ឋសភា ដើម្បីដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាពិនិត្យសម្រេច ហើយបញ្ជូនសេចក្តីស្នើថវិកានោះទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដាក់បញ្ចូលទៅក្នុងគម្រោងថវិកាជាតិតាមការកំណត់ក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។

រាល់ការចំណាយថវិការបស់រដ្ឋសភា ត្រូវមានតម្លាភាព និងជានាផ្តល់សេវាប្រកបដោយប្រសិទ្ធភាព និងសមធម៌ជូនដល់រដ្ឋសភា គណៈកម្មការនានារបស់រដ្ឋសភា ថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សនយោបាយ និងសមាជិករដ្ឋសភា ។

បែបបទចំណាយថវិការបស់រដ្ឋសភា ត្រូវកំណត់ដោយសេចក្តីសម្រេចប្រចាំឆ្នាំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ។

អគ្គលេខាធិការដ្ឋានរដ្ឋសភា ទទួលខុសត្រូវធ្វើរបាយការណ៍ចំណាយថវិការដ្ឋសភានៅរាល់ ៦ខែម្តង និងក្នុងរាល់ដំណាច់ឆ្នាំ និងដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាពិនិត្យសម្រេចក្រោយពីមាន

*ការវាយតម្លៃ និងសេចក្តីសន្និដ្ឋានពីគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ព្រមទាំងមានការចូលរួមពីតំណាងគណៈកម្មការនានារបស់រដ្ឋសភាផង លើកលែងតែរបាយការណ៍ទូទាត់ថវិកាដំណាច់ឆ្នាំ ក្រោយពីគណៈកម្មាធិការអចិន្ត្រៃយ៍ពិនិត្យសម្រេចហើយត្រូវបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីរៀបចំបញ្ចូលក្នុងសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ ។*

## ជំពូកទី ៩
## អំពីសំណួរ និងចម្លើយ

**ប្រការ ៣២** :

*អ្នកតំណាងរាស្ត្រមានសិទ្ធិដាក់សំណួរដល់រាជរដ្ឋាភិបាល ។ សំណួរនេះត្រូវសរសេរជាលាយលក្ខណ៍អក្សរប្រគល់ជូនតាមរយៈប្រធានរដ្ឋសភា ។*

*ចម្លើយអាចធ្វើឡើងដោយរដ្ឋមន្ត្រីមួយរូប ឬច្រើនរូបអាស្រ័យដោយបញ្ហាដែលបានចោទឡើងពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់រដ្ឋមន្ត្រីមួយរូប ឬច្រើនរូប ។ បើបញ្ហាពាក់ព័ន្ធដល់នយោបាយទូទៅរបស់រាជ-រដ្ឋាភិបាលនាយករដ្ឋមន្ត្រីត្រូវឆ្លើយផ្ទាល់ខ្លួន ។*

*ចម្លើយរបស់រដ្ឋមន្ត្រី ឬរបស់នាយករដ្ឋមន្ត្រី អាចធ្វើដោយផ្ទាល់មាត់ ឬសរសេរជាលាយលក្ខណ៍អក្សរ ។*

*ចម្លើយខាងលើនេះត្រូវធ្វើឡើងក្នុងរយៈពេលប្រាំពីរថ្ងៃបន្ទាប់ពីបានទទួលសំណួរ ។*

*ចំពោះចម្លើយផ្ទាល់មាត់ ប្រធានរដ្ឋសភាអាចសម្រេចបើកឲ្យមាន ឬមិនឲ្យមានការជជែកដេញដោល ។ បើគ្មានការបើកឲ្យជជែកដេញដោលទេនោះ ចម្លើយរបស់រដ្ឋមន្ត្រី ឬរបស់នាយករដ្ឋមន្ត្រីនឹងបញ្ចប់សំណួរតែម្តង ។*

**ប្រការ ៣៣ ថ្មី** (**ពីរ**) :

*តំណាងរាស្ត្រដែលបានតាំងសំណួរចំពោះរដ្ឋមន្ត្រីណាមួយអាចសុំដកលិខិតតាំងសំណួររបស់ខ្លួនចេញបាន ។*

*តំណាងរាស្ត្រឯទៀតអាចទទួលពាក្យសុំតាំងសំណួរដែលដកចេញហើយនោះទៅជូនប្រធានរដ្ឋសភាសាជាថ្មីទៀតបានកាលបើយល់ឃើញថាចាំបាច់ ។*

*បើមានការបើកឲ្យជជែកដេញដោល ម្ចាស់សំណួរ វាគ្មិនឯទៀត និងរដ្ឋមន្ត្រីពាក់ព័ន្ធនាយករដ្ឋមន្ត្រីអាចជជែកប្តូរយោបល់ក្នុងរយៈពេលដែលមិនអាចលើសពីមួយពេលប្រជុំឡើយ ។ រដ្ឋសភាកំណត់ទុករយៈ-ពេលមួយថ្ងៃក្នុងមួយសប្តាហ៍សម្រាប់ការតាំង និងការឆ្លើយសំណួរ ។ ការប្រជុំនេះមិនទាមទារកូរ៉ុមទេ ។*

*បើសំណួរ ចំលើនាយករដ្ឋមន្ត្រី នាយករដ្ឋមន្ត្រី ឬតំណាងក្នុងករណីនាយករដ្ឋមន្ត្រីមានធុរៈត្រូវមកឆ្លើយសំណួរ ។*

*បើសំណួរ ចំលើសមាជិករាជរដ្ឋាភិបាលរូបណាសមាជិករូបនោះត្រូវមកឆ្លើយសំណួរនៅរដ្ឋសភា ។*

*ទោះបីជាយ៉ាងណាក៏ដោយ សម័យប្រជុំសម្រាប់ឆ្លើយសំណួរខាងលើនេះ មិនអាចបើកលទ្ធភាពឲ្យមានការបោះឆ្នោតប្រភេទណាមួយបានឡើយ ។*

*បែបបទ និងនីតិវិធីនៃសំណួរ និងចម្លើយត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធានរដ្ឋសភា ។*

**ប្រការ ៣៤ ថ្មី** :

*គណៈកម្មការទាំងឡាយរបស់រដ្ឋសភាអាចអញ្ជើញរដ្ឋមន្ត្រីណាមួយមកបំភ្លឺអំពីបញ្ហាអ្វីមួយដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួន ។*

**ប្រការ ៣៥ ថ្មី** :

*រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីតំណែង ដោយអនុម័តញត្តិបន្ទោស តាមសំឡេងឆ្នោតភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។*

*ញត្តិបន្ទោសរាជរដ្ឋាភិបាលត្រូវបានលើកឡើងជូនរដ្ឋសភាដោយតំណាងរាស្ត្រចំនួនសាមសិបនាក់យ៉ាងតិចទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន ។*

## ជំពូកទី ១០
## អំពីការបញ្ចេញមតិ

**ប្រការ ៣៦ ថ្មី(ពីរ)** :

*ក្នុងបញ្ហាទាំងឡាយដែលរដ្ឋសភាត្រូវពិនិត្យ រដ្ឋសភាបញ្ចេញមតិដោយវិធី ៣ យ៉ាង គឺដោយលើកដៃ ឬដោយបោះឆ្នោតចំហ ឬដោយបោះឆ្នោតសម្ងាត់ ។*

*វិធីបញ្ចេញមតិដោយលើកដៃ ឬដោយបោះឆ្នោតចំហខាងលើនេះ អាចធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិច ។*

**ប្រការ ៣៧** :

*ចំពោះការបញ្ចេញមតិដោយវិធីលើកដៃប្រធាន និងលេខាធិការទាំងឡាយជាអ្នករាប់ចំនួនសមាជិកដែលលើកដៃ ។ បើប្រធាន និងលេខាធិការ ទាំងនោះឃើញថាការបញ្ចេញមតិមិនបានលទ្ធផលច្បាស់លាស់ទេនោះត្រូវបញ្ចេញមតិ និងរាប់សាជាថ្មីទៀត ។*

**ប្រការ ៣៨ ថ្មី(ពីរ)** :

*កាលបើការបញ្ចេញមតិដោយលើកដៃបានធ្វើពីរដងហើយនៅតែមិនទាន់បានលទ្ធផលច្បាស់លាស់ទេនោះត្រូវប្រើវិធីបោះឆ្នោតជាចំហ ។*

*វិធីបោះឆ្នោតចំហនេះត្រូវធ្វើដូចតទៅ* :

អាជ្ញាសភាដែលជាមន្ត្រីចាត់តាំងដោយអគ្គលេខាធិការរដ្ឋសភា កាន់ហិបឆ្នោតដើរទទួលប្រមូលយកសន្លឹកឆ្នោតពីសមាជិករដ្ឋសភា ។ សមាជិករដ្ឋសភា ត្រូវសរសេរឈ្មោះខ្លួនលើសន្លឹកឆ្នោតនោះ ។ សន្លឹកឆ្នោតមានបីយ៉ាង : ពណ៌សសម្គាល់ថាព្រម ពណ៌ខៀវសម្គាល់ថា មិនព្រម និងពណ៌ស ឆ្នូតខៀវសម្គាល់ថាអនុបវាទ ។

ក្រោយពីបោះឆ្នោតរួចស្រេចហើយលេខាធិការរាប់សន្លឹកឆ្នោត ។ លុះរាប់សន្លឹកឆ្នោតរួចហើយ ប្រធានរដ្ឋសភាត្រូវប្រកាសលទ្ធផលជូនអង្គសភា ។

**ប្រការ ៣៩** :

វិធីបោះឆ្នោតចំហនៅវេទិកាប្រព្រឹត្តទៅដូចតទៅនេះ :

អ្នកតំណាងរាស្ត្រម្នាក់ៗដើរយកសន្លឹកឆ្នោតមកបោះក្នុងហិបដែលដាក់នៅលើវេទិកា ។

វិធីនេះនឹងយកមកប្រើបានលុះត្រាតែមានអ្នកតំណាងរាស្ត្រ ១០នាក់ យ៉ាងតិចស្នើសុំ ។

**ប្រការ ៤០ ថ្មី (ពីរ)** :

វិធីបោះឆ្នោតសម្ងាត់ត្រូវតែប្រើក្នុងការជ្រើសតាំង ការសម្តែងការទុកចិត្ត និងក្នុងការអនុម័តញត្តិបន្ទោស វៀរលែងតែមានកំណត់ក្នុងច្បាប់ធម្មនុញ្ញបន្ថែមសំដៅជានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ។

*ការអនុម័តច្បាប់ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញអាចប្រព្រឹត្ត ដោយវិធីបោះឆ្នោតសម្ងាត់ដែរ ។*

*សម្រាប់ការបោះឆ្នោតសម្ងាត់ លេខាធិការអង្គប្រជុំត្រូវចាប់ឆ្នោតជ្រើសរើសសមាជិកប្រាំរូប ក្នុងចំណោមឈ្មោះសមាជិករដ្ឋសភាវត្តមានដើម្បីរៀបចំជាគណៈកម្មការបោះឆ្នោត ។*

**ប្រការ ៤១ ថ្មី** :

*ការអនុម័តទាំងឡាយត្រូវយកតាមមតិភាគច្រើន ដែលមានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ។ ក្រៅពីនេះមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ត្រូវទុកជាបានការ វៀរលែងតែមានការកំណត់ក្នុងច្បាប់ដោយឡែក ។*

**ប្រការ ៤២** :

*បើចំនួនមតិយល់ព្រម និងចំនួនមតិមិនយល់ព្រមស្មើគ្នា ការបោះឆ្នោតត្រូវធ្វើម្តងទៀត ។ បើលទ្ធផលនៃការបោះឆ្នោតលើកទី ២ នៅតែស្មើគ្នាត្រូវទុកថារដ្ឋសភាមិនយល់ព្រម។*

**ប្រការ ៤៣** :

*ក្រោយបានលទ្ធផល នៃការបញ្ចេញមតិរួចហើយ ប្រធានរដ្ឋសភាត្រូវប្រកាសថារដ្ឋសភាបានអនុម័តយល់ព្រមហើយ ឬថារដ្ឋសភាបានអនុម័តមិនយល់ព្រមទេ ។*

## ជំពូកទី ១១
## អំពីការប្រកាសការប្រញាប់

**ប្រការ ៤៤** :

*សេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ ឬញត្តិណាមួយដែលត្រូវបានប្រកាសថាជាការប្រញាប់ ត្រូវចុះក្នុងរបៀបវារៈពិភាក្សាមុនគេ ។*

**ប្រការ ៤៥** :

*ការប្រញាប់នេះអាចស្នើសុំឡើងដោយរាជរដ្ឋាភិបាលដោយម្ចាស់សេចក្តីស្នើច្បាប់ ឬដោយម្ចាស់ញត្តិ ។*

*រដ្ឋសភាត្រូវសម្រេចលើពាក្យសុំដែលមានចែងក្នុងប្រការខាងលើនេះ ។*

**ប្រការ ៤៦** :

*អ្នកសុំឲ្យប្រកាសទុកជាការប្រញាប់ត្រូវជូនហេតុផលមកផង ។ ប្រធាននាំសេចក្តីនោះទៅថ្លែងជម្រាបរដ្ឋសភា ហើយរដ្ឋសភាសម្រេចថាយល់ព្រមទុកជាការប្រញាប់ ឬមិនយល់ព្រម ។*

## ជំពូកទី ១២ ថ្មី(មួយ)
## អំពីរបៀបប្រជុំ និងអាសនានុក្រម នៃក្រុមតំណាងរាស្ត្រ

**ប្រការ ៤៧ ថ្មី** (**បួន**) :

*ការប្រជុំរដ្ឋសភាត្រូវធ្វើជាសាធារណៈ ។*

*ការប្រជុំរដ្ឋសភានឹងយកជាការបានលុះត្រាតែមាន :*

**ក**-*កូរ៉ុមលើសពីពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឲ្យយកមតិភាគច្រើន ពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។*

**ខ**-*កូរ៉ុមលើសពីពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឲ្យយកមតិភាគច្រើនដោយប្រៀប ឬយកមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។*

*សមាជិកដែលអវត្តមានត្រូវបានចុះក្នុងបញ្ជីអវត្តមានហើយបញ្ជីនេះត្រូវបានប្រកាសដោយប្រធាន ដោយបញ្ជាក់អំពីមូលហេតុផង ។*

*ប្រធានរដ្ឋសភាត្រូវផ្អាកការប្រជុំ បើកូរ៉ុមមិនគ្រប់ក្នុងរយៈពេល ១៥ (ដប់ប្រាំ) នាទី បន្ទាប់ពីហួសពេលកំណត់នៃការចាប់ផ្តើមប្រជុំ ។*

**ប្រការ ៤៨ ថ្មី (បួន)** :

*អាសនានុក្រមនៃក្រុមតំណាងរាស្ត្រ ត្រូវរៀបជាក្រុមៗតាមគណបក្សនយោបាយពីមុខទៅក្រោយ ។ ក្រុមនីមួយៗ ត្រូវមានសមាជិកយ៉ាងតិចដប់រូប ។ តំណាងរាស្ត្រមួយរូបអាចចូលជាសមាជិករបស់ក្រុមតែមួយប៉ុណ្ណោះ ។ ក្រុមនីមួយៗ ត្រូវមានប្រធានមួយរូបអនុប្រធានមួយរូប ។ គណបក្សនយោបាយណាមានអាសនៈតិចជាងដប់ ត្រូវជ្រើសរើសក្រុមណាមួយដែលខ្លួនពេញចិត្តនៅជាមួយ ។ បញ្ជីរាយនាមរបស់*

*ក្រុមតំណាងរាស្ត្រ នៃគណបក្សនយោបាយត្រូវផ្ញើជូនប្រធានរដ្ឋសភា ។*

**ប្រការ ៤៩** :

*ការកំណត់ថ្ងៃប្រជុំត្រូវធ្វើជាលិខិតផ្ញើទៅជូនអ្នកតំណាងរាស្ត្រ ។ បើការកំណត់ដោយផ្ទាល់មាត់ក្នុងពេលប្រជុំការកំណត់នេះត្រូវធ្វើជាលិខិតផ្ញើទៅជូនតំណាងរាស្ត្រ ដែលមិនបានមកប្រជុំ ។*

*តាមធម្មតា ពេលប្រជុំត្រូវកំណត់យ៉ាងតិច ២ថ្ងៃមុនវៀរលែងតែក្នុងការប្រញាប់ ។*

**ប្រការ ៥០** :

*លិខិតអញ្ជើញត្រូវមានភ្ជាប់ទៅជាមួយនូវរបៀបវារៈប្រជុំវៀរលែងតែក្នុងការប្រញាប់ ។*

**ប្រការ ៥១ ថ្មី** :

*ក្នុងករណីដែលប្រធាន ឬអនុប្រធានរដ្ឋសភា លាលែងពីមុខតំណែង ឬអនិច្ចកម្ម រដ្ឋសភាត្រូវបោះឆ្នោតជ្រើសតាំងប្រធាន ឬអនុប្រធានថ្មី ។*

**ប្រការ ៥២** :

*បើមានបញ្ហាអ្វីនឹងថ្លែងជម្រាបរដ្ឋសភានោះ ប្រធានអាចថ្លែងមុននឹងចាប់ផ្ដើមការតាមរបៀបវារៈ ។*

**ប្រការ ៥៣** :

*តាមធម្មតា ការប្រជុំត្រូវដំណើរការជាលំដាប់តាមរបៀបវារៈ វៀរលែងតែក្នុងពេលប្រជុំខ្លះដែលអង្គសភាសម្រេចផ្សេងពីនេះ ។*

*មុននឹងចាប់ផ្តើមសម័យប្រជុំ រដ្ឋសភាអនុម័តរបៀបវារៈ និងសមាសភាពគណៈលេខាសម្រាប់សម័យប្រជុំ ។*

**ប្រការ ៥៤** :

*បើប្រធានយល់ឃើញថាជាការមានប្រយោជន៍ ឬជាការចាំបាច់ ឬបើមានអ្នកតំណាងរាស្ត្រ ១០ នាក់ យ៉ាងតិចស្នើសុំប្រធានអាចលើកពេលប្រជុំបាន ។*

**ប្រការ ៥៥ ថ្មី** :

*តំណាងរាស្ត្រក្នុងក្រុមនីមួយៗ ត្រូវសុំតាមរយៈតំណាងក្រុមរបស់ខ្លួនហើយទទួលសេចក្តីអនុញ្ញាតពីប្រធានរដ្ឋសភាជាមុនសិនទើបនិយាយបាន ។*

**ប្រការ ៥៦ ថ្មី** :

*តាមធម្មតាលេខាធិការត្រូវកត់ឈ្មោះតំណាងរាស្ត្រក្នុងក្រុមនីមួយៗ ដែលសុំនិយាយជាលំដាប់តាមសុំមុនសុំក្រោយ ។*

**ប្រការ ៥៧** :

*ក្នុងការជជែកពិភាក្សា វាគ្មិនត្រូវនិយាយឆ្លាស់គ្នា អ្នកគាំទ្រ*

*និយាយម្តងរួចអ្នកជំទាស់និយាយម្តង ។*

**ប្រការ ៥៨ ថ្មី** :

*តាមគោលការណ៍ រយៈពេលនិយាយសម្រាប់តំណាងរាស្ត្រក្នុងក្រុមនីមួយៗត្រូវមានកំណត់ ហើយត្រូវនិយាយតែពីប្រធានបទដែលកំពុងពិភាក្សា ។ បើនិយាយក្រៅប្រធានបទ ប្រធានត្រូវរំលឹកឲ្យធ្វើតាមរបៀបខាងលើនេះវិញ ។ បើតំណាងរាស្ត្រក្នុងក្រុមនោះ នៅចចេសនិយាយក្រៅប្រធានបទដដែល ប្រធានអង្គប្រជុំអាចបញ្ឈប់វាគ្មិននោះកុំឲ្យនិយាយបន្តទៅទៀត ។*

**ប្រការ ៥៩ ថ្មី** :

*តាមធម្មតាតំណាងរាស្ត្រក្នុងក្រុមដែលបានចុះឈ្មោះសុំនិយាយ និយាយបានម្ភៃនាទីយ៉ាងយូរ ។ តំណាងរាស្ត្រក្នុងក្រុមដែលគ្រាន់តែសុំឆ្លើយតប និយាយបានតែប្រាំនាទីទេ ។*

*បើប្រធានយល់ឃើញថាជាការចាំបាច់ ឬជាការមានប្រយោជន៍ក្នុងការពិភាក្សា នោះប្រធានអាចអនុញ្ញាតបន្ថែមពេលឲ្យនិយាយដប់នាទីទៀតបាន ។ ការបន្ថែមនេះអាចអនុញ្ញាតឲ្យបន្តបានពីរដងក្នុងប្រធានបទដដែល ។*

*តំណាងរាស្ត្រឯទៀតក្នុងក្រុមជាមួយមានសិទ្ធិសុំបញ្ចេញមតិបន្ថែមក្នុងប្រធានបទដដែល និងក្នុងរយៈពេលដែលនៅសល់ពីការកំណត់ខាងលើ ។*

**ប្រការ ៦០ ថ្មី** :

*បទប្បញ្ញត្តិអំពីការចុះឈ្មោះសុំនិយាយជាលំដាប់គ្នានិងអំពីកំណត់ រយៈពេលនិយាយនេះ ប្រើសម្រាប់តែតំណាងរាស្ត្រក្នុងក្រុមមិនត្រូវប្រើសម្រាប់ម្ចាស់សេចក្តីព្រាងច្បាប់ ឬម្ចាស់សេចក្តីស្នើច្បាប់ទេ ។*

**ប្រការ ៦១** :

*បើមានការជ្រួលច្របល់ក្នុងពេលប្រជុំ ហើយប្រធានហាមពុំស្តាប់ នោះប្រធានអាចលើកពេលប្រជុំ ដោយក្រោកដើរចេញពីសាលប្រជុំ ។*

**ប្រការ ៦២** :

*ហាមមិនឲ្យនិយាយកាត់ពាក្យអ្នកដទៃមិនឲ្យនិយាយវាយប្រហារលើបុគ្គលមិនឲ្យសំដែងអាការៈផ្សេងៗ ដែលនាំឲ្យខូចសណ្តាប់ធ្នាប់ ។*

## ជំពូកទី ១៣
## អំពីការរក្សាសេចក្តីស្ងប់ក្នុងពេលប្រជុំ

**ប្រការ ៦៣** :

*ប្រធានរដ្ឋសភាមានភារៈរក្សាការពារមិនឲ្យមានភយន្តរាយខាងក្នុងក្តីមកពីខាងក្រៅក្តីដែលកើតមានឡើងដល់រដ្ឋសភា ។ ដើម្បីធ្វើឲ្យសម្រេចកិច្ចនេះ ប្រធានរដ្ឋសភាអាចប្រើកម្លាំងនគរបាល ឬសុំអន្តរាគមន៍ពីកម្លាំងទ័ព ។*

**ប្រការ ៦៤** :

*ការថែរក្សាការពារសេចក្ដីសុខសាន្ដរបស់រដ្ឋសភា ត្រូវធ្វើឡើងដោយប្រធានរដ្ឋសភាក្នុងនាមរដ្ឋសភា ។ ជាគោលការណ៍ប្រធានរដ្ឋសភាអនុញ្ញាតឲ្យសាធារណជនចូលក្នុងសាលប្រជុំបានតាមចំនួនកន្លែងដែលមាន ។ ប៉ុន្ដែបើជនណាធ្វើឲ្យរង្វៀសតាមវិធីណាក្ដីដល់ការពិភាក្សារបស់អង្គសភា ប្រធានអាចបញ្ជាឲ្យបណ្ដេញចេញភ្លាម ។*

**ប្រការ ៦៥** :

*កាលបើអង្គសភាសម្រេចថាត្រូវប្រជុំជាសម្ងាត់នោះមុននឹងបើកពេលប្រជុំ ប្រធានរដ្ឋសភា និងលេខាធិការត្រូវត្រួតមើលឲ្យជាក់ច្បាស់ជាមុនសិនថាពិតជាគ្មានមនុស្សដទៃនៅក្នុងបន្ទប់ប្រជុំទេ ។*

## ជំពូកទី ១៤
## អំពីការខានមកប្រជុំ

**ប្រការ ៦៦** :

*ក្នុងពេលប្រជុំនីមួយៗ លេខាធិការស្រង់ឈ្មោះអ្នកតំណាងរាស្ដ្រដែលអវត្តមាន ដោយបញ្ជាក់អំពីមូលហេតុនៃអវត្តមាននេះ ។*

**ប្រការ ៦៧** :

*អ្នកតំណាងរាស្ដ្រមិនអាចអវត្តមាន ដោយមិនមានការអនុញ្ញាតពីប្រធានរដ្ឋសភាបានឡើយ ។*

**ប្រការ ៦៨** :

*ប្រធានអាចអនុញ្ញាតឲ្យសមាជិករដ្ឋសភាឈប់បានយ៉ាងយូររួមទាំងអស់ ១៥ថ្ងៃ ក្នុងសម័យប្រជុំនីមួយៗ ។ ការឈប់លើសពី ១៥ថ្ងៃ ត្រូវសុំឲ្យអង្គសភាអនុម័តយល់ព្រម ។*

**ប្រការ ៦៩** :

*អ្នកតំណាងរាស្ត្ររូបណាដែលអវត្តមានដោយមូលហេតុមានជម្ងឺរយៈពេល ៥ថ្ងៃ ជាប់ៗគ្នា ត្រូវមានសំបុត្រពេទ្យយកមកជាសំអាង ។*

**ប្រការ ៧០** :

*តំណាងរាស្ត្រណាឈប់ខានមកប្រជុំលើសពី បីថ្ងៃ ដោយគ្មានការអនុញ្ញាត ត្រូវកាត់ប្រាក់បំណាច់រដ្ឋសភា ចំពោះថ្ងៃដែលអវត្តមាននោះ ។*

**ប្រការ ៧១** :

*អ្នកតំណាងរាស្ត្ររូបណាបានទទួលការអនុញ្ញាតឲ្យឈប់ ហើយឈប់លើសចំនួនថ្ងៃអនុញ្ញាតនោះត្រូវកាត់ប្រាក់បំណាច់ចំពោះថ្ងៃដែលឈប់លើសពីការអនុញ្ញាត ។*

**ប្រការ ៧២** :

*កាលបើមានសេចក្តីអញ្ជើញមកប្រជុំតាមបទប្បញ្ញត្តិនៃប្រការ ៤៩ ហើយអ្នកតំណាងរាស្ត្រមិនបានមកប្រជុំដោយឥតមានមូលហេតុ*

យកជាការបានអ្នកតំណាងរាស្ត្រនោះត្រូវទទួលទណ្ឌកម្មខាងវិន័យដូចខាងក្រោមនេះ :

**ក**-ការខានមកប្រជុំលើសពី ២ថ្ងៃ ត្រូវព្រមាន ។

**ខ**-បើបានទទួលការព្រមានដល់ទីលំនៅហើយ ហើយនៅតែមិនចូលមកប្រជុំនោះត្រូវកាត់ប្រាក់បំណាច់រដ្ឋសភាតាមចំនួនថ្ងៃអវត្តមាន ។ ទណ្ឌកម្មខាងវិន័យនេះត្រូវ ប្រគល់ដល់ទីលំនៅរបស់សាមីខ្លួន ។

**គ**-បើបានទទួលដំណឹងលើកក្រោយនេះហើយ ហើយនៅតែមិនចូលមកប្រជុំ ឬមិនផ្តល់សេចក្តីដោះសារដោយមានមូលហេតុយកជាការបាននោះ ត្រូវដាក់ទណ្ឌកម្ម ខាងវិន័យទី ៣ គឺកាត់ប្រាក់បំណាច់រដ្ឋសភាតាមចំនួនថ្ងៃអវត្តមាន ហើយថែមទាំងបណ្តេញចេញពីការប្រជុំចំនួន ១៥ថ្ងៃ ។

បើបានទទួលទណ្ឌកម្មខាងវិន័យទាំង៣យ៉ាងខាងលើនេះហើយ ហើយក្នុងរវាងមួយខែក្រោយមក អ្នកតំណាងរាស្ត្រដដែលនៅតែប្រព្រឹត្តខុសទៀតត្រូវធ្វើទណ្ឌកម្មខាងវិន័យជាទម្ងន់ ដោយកាត់ប្រាក់បំណាច់តាមចំនួនថ្ងៃដែលអវត្តមាន និងបណ្តេញពីការប្រជុំរយៈពេលមួយខែប្រកាសផ្សាយដល់មហាជននៅក្នុងមណ្ឌល នៃអ្នកតំណាងរាស្ត្រ ដែលបានប្រព្រឹត្តខុស ។

គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាជាអ្នកដាក់ទណ្ឌកម្មខាងវិន័យដោយស្វ័យប្រវត្តិកាលបើបានដឹងច្បាស់ថាហេតុដែលខានមកប្រជុំនោះមិនអាចយកជាការបាន វៀរលែងតែករណីដែលរដ្ឋសភាបានទទួល

*ពាក្យតវ៉ាសមហេតុផល អំពីសាមីខ្លួនក្នុងពេលប្រជុំពេញអង្គ ។*

## ជំពូកទី ១៥
## អំពីវិន័យ

**ប្រការ ៧៣** :

*ទណ្ឌកម្មខាងវិន័យដែលយកមកប្រើចំពោះអ្នកតំណាងរាស្ត្រមានដូចតទៅ :*

**ក**-*ក្រើនរំលឹក*

**ខ**-*ក្រើនរំលឹកដោយចុះក្នុងកំណត់ហេតុ*

**គ**-*បន្ទោស*

**ឃ**-*បន្ទោសហើយបណ្តេញចេញមួយរយៈពេលពីសាលប្រជុំ ។*

**ប្រការ ៧៤** :

*ប្រធានរដ្ឋសភាត្រូវក្រើនរំលឹកវាគ្មិនណាដែលប្រព្រឹត្តខុស ឬអ្នកតំណាងរាស្ត្រណាដែលធ្វើឲ្យខូចសណ្តាប់ធ្នាប់ ដោយល្មើសនឹងបទប្បញ្ញត្តិនៃប្រការ ៦២ នៃបទបញ្ជាផ្ទៃក្នុងនេះ ។*

**ប្រការ ៧៥** :

*អ្នកតំណាងរាស្ត្រណាដែលត្រូវបានក្រើនរំលឹកមួយដងហើយហើយនៅតែប្រព្រឹត្តខុសដដែលទៀតនៅក្នុងពេលប្រជុំតែមួយនោះប្រធានរដ្ឋសភាត្រូវក្រើនរំលឹកម្តងទៀត ដោយចុះសេចក្តីក្រើនរំលឹក*

*នោះទុកក្នុងកំណត់ហេតុនៃអង្គប្រជុំ ។*

**ប្រការ ៧៦** :

*អ្នកតំណាងរាស្ត្រណាដែលត្រូវបានក្រើនរំលឹកហើយមានចុះក្នុងកំណត់ហេតុផង ត្រូវបានកាត់ប្រាក់បំណាច់ប្រចាំខែចំនួនមួយភាគបួន ។*

**ប្រការ ៧៧** :

*អ្នកតំណាងរាស្ត្រដែលត្រូវបន្ទោសនោះគឺ :*

**ក**-*អ្នកតំណាងរាស្ត្រណា ដែលប្រធានបានក្រើនរំលឹកព្រមទាំងចុះសេចក្តីក្នុង កំណត់ហេតុហើយ ហើយនៅតែមិនរាងចាល ។*

**ខ**-*អ្នកតំណាងរាស្ត្រណាដែលត្រូវបានក្រើនរំលឹក ៣ដងហើយ ហើយនៅតែធ្វើខុសដដែលក្នុងវេលា ៣០ថ្ងៃ ។*

**គ**-*អ្នកតំណាងរាស្ត្រណាដែលនាំអាទ៍ឲ្យមានការជ្រួលច្របល់ក្នុងសាលប្រជុំ ឬនាំអាទ៍អ្នកតំណាងរាស្ត្រច្រើនគ្នាកុំឲ្យរួមធ្វើការក្នុងរដ្ឋសភា ។*

**ឃ**-*អ្នកតំណាងរាស្ត្រណាដែលជេរប្រមាថមើលងាយ ឬបង្កជម្លោះ ឬគំរាមកំហែងអ្នកតំណាងរាស្ត្រឯទៀត ។*

**ប្រការ ៧៨** :

*អ្នកតំណាងរាស្ត្រដែលត្រូវបន្ទោសហើយបណ្តេញចេញមួយរយៈពេលពីអង្គប្រជុំគឺ :*

**ក**-*អ្នកតំណាងរាស្ត្រដែលត្រូវបន្ទោសហើយនៅតែមិនរាងចាល ។*

**ខ**-*អ្នកតំណាងរាស្ត្រដែលញុះញង់ឲ្យប្រើហឹង្សា ។*

**គ**-*អ្នកតំណាងរាស្ត្រដែលជេរប្រមាថមើលងាយរដ្ឋសភា ឬប្រធានរដ្ឋសភា ។*

**ឃ**-*អ្នកតំណាងរាស្ត្រដែលប្រព្រឹត្តខុស ដោយប្រមាថមើលងាយព្រះមហាក្សត្រ ។*

**ប្រការ ៧៩** :

*ការបន្ទោស ឬការបន្ទោសហើយបណ្តេញចេញផង ត្រូវអនុម័តដោយអង្គសភា តាមវិធីលើកដៃ ឬបោះឆ្នោតចំហ តាមសេចក្តីស្នើពីប្រធានរដ្ឋសភា ។*

**ប្រការ ៨០** :

*ការបន្ទោសនាំឲ្យទទួលទណ្ឌកម្មដូចតទៅ:*

**ក**-*កាត់ប្រាក់បំណាច់ប្រចាំខែចំនួនហាសិបភាគរយ*

**ខ**-*ប្រកាសផ្សាយជាសាធារណៈនូវសម្រេចកំណត់ហេតុបន្ទោសព្រមទាំងយកទៅបោះពុម្ព ហើយបិទនៅគ្រប់ឃុំក្នុងមណ្ឌលរបស់អ្នកតំណាងរាស្ត្រដែលមានកំហុស ។*

**ប្រការ ៨១** :

*ការបន្ទោសហើយបណ្តេញផងនាំឲ្យទទួលទណ្ឌកម្មដូចតទៅ :*

**ក**-*កាត់ប្រាក់បំណាច់ប្រចាំខែហាសិបភាគរយក្នុងរយៈពេល២ខែ ។*

*ខ-ប្រកាសផ្សាយជាសាធារណៈនូវសេចក្ដីសម្រេចកំណត់ហេតុបន្ទោស ព្រមទាំងយកទៅបោះពុម្ព ហើយបិទនៅគ្រប់ឃុំក្នុងមណ្ឌលរបស់អ្នកតំណាងរាស្ត្រដែលមានកំហុស ។*

*គ-ហាមមិនឲ្យចូលមកធ្វើការក្នុងរដ្ឋសភាក្នុងវេលា ១៥ ពេលប្រជុំជាបន្តបន្ទាប់ ។*

## ជំពូកទី ១៦
## អំពីការសុំកែប្រែបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា

**ប្រការ ៨២ ថ្មី** :

*បទបញ្ជាផ្ទៃក្នុងនេះនឹងកែប្រែបានលុះត្រាតែមានសេចក្ដីស្នើសុំពីអ្នកតំណាងរាស្ត្រមួយភាគបួនយ៉ាងតិច នៃចំនួនសមាជិករដ្ឋសភាទាំងមូល ហើយត្រូវបានអនុម័តយល់ព្រមដោយសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។*

## ជំពូកទី ១៧
## អន្តរប្បញ្ញត្តិ

**ប្រការ ៨៣ ថ្មី** :

*អាសនៈរបស់តំណាងរាស្ត្រដែលនៅទំនេរ ដោយសុំលាលែង ដោយបោះបង់ចោលការងារចំនួនបីខែគ្មានការអនុញ្ញាត ដោយទទួលមរណភាព ដោយប្រាសចាកសមាជិកភាពរដ្ឋសភា ឬដោយប្រាសចាក*

សមាជិកភាពពីគណបក្សជាប់ឆ្នោត ត្រូវបំពេញជំនួសដោយតំណាង រាស្ត្រថ្មីលំដាប់លេខរៀងបន្ទាប់ដែលជ្រើសរើសក្នុងបញ្ជីបេក្ខជនឈរ ឈ្មោះតំណាងគណបក្សក្នុងមណ្ឌលជាមួយគ្នា ។

## គណៈកម្មការរៀបរៀង
## បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា

| | | |
|---|---|---|
| ១-*ឯកឧត្តម* | **អ៊ឹង គៀត** | *ប្រធាន* |
| ២-*ឯកឧត្តម* | **ចែម ស្គួន** | *អនុប្រធាន* |
| ៣-*ឯកឧត្តមបណ្ឌិត* | **តាង សេងហួរ** | *អ្នករាយការណ៍* |
| ៤-*ឯកឧត្តម* | **យូ ហុកគ្រី** | *សមាជិក* |
| ៥-*ឯកឧត្តម* | **ចៅ ប៉េងលាត** | *សមាជិក* |
| ៦-*ឯកឧត្តម* | **ឈួរ លាងហួត** | *សមាជិក* |
| ៧-*ឯកឧត្តម* | **អ៊ឹង ហួត** | *សមាជិក* |
| ៨-*ឯកឧត្តម* | **ស៊ឹន ស៊ីមៃត្រី** | *សមាជិក* |
| ៩-*ឯកឧត្តម* | **ជាម យៀប** | *សមាជិក* |
| ១០-*ឯកឧត្តម* | **កាន់ ម៉ន** | *សមាជិក* |
| ១១-*ឯកឧត្តម* | **ឈាង វុន** | *សមាជិក* |
| ១២-*ឯកឧត្តម* | **ម៉ៅញ្ញ សាផាន** | *សមាជិក* |
| ១៣-*ឯកឧត្តម* | **ឡូយ ស៊ីមឈាង** | *សមាជិកបំរុង* |
| ១៤-*ឯកឧត្តម* | **ប៊ិន ឈិន** | *សមាជិកបំរុង* |
| ១៥-*ឯកឧត្តម* | **សេរី កុសល** | *សមាជិកបំរុង* |
| ១៦-*ឯកឧត្តម* | **សរ សារអាត** | *សមាជិកបំរុង* |
| ១៧-*ឯកឧត្តម* | **ប៉ុល ហំម** | *សមាជិកបំរុង* |
| ១៨-*ឯកឧត្តម* | **ឯក សំអុល** | *សមាជិកបំរុង* |
| ១៩-*ឯកឧត្តម* | **ឈឹម សៀកឡេង** | *សមាជិកបំរុង* |

## គណៈកម្មការពិសេសចំពោះកិច្ច
## ដើម្បីកែលំអបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា

| | | |
|---|---|---|
| **១**-*ឯកឧត្តម* | **ខួន ញ៉ឹល** | *ប្រធាន* |
| **២**-*ឯកឧត្តម* | **ម៉ៅញ្ញ សាផាន** | *អនុប្រធាន* |
| **៣**-*ឯកឧត្តម* | **ឯក សំអុល** | *អ្នករាយការណ៍* |
| **៤**-*លោកជំទាវ* | **គ លំអង** | *សមាជិកា* |
| **៥**-*ឯកឧត្តម* | **ប៉ែន បញ្ញា** | *សមាជិក* |
| **៦**-*ឯកឧត្តម* | **លី ធុជ** | *សមាជិក* |
| **៧**-*លោកជំទាវ* | **ហូ ណូន** | *សមាជិកា* |
| **៨**-*ឯកឧត្តម* | **ខៀវ សន** | *សមាជិក* |
| **៩**-*ឯកឧត្តម* | **លី សុន** | *សមាជិក* |
| **១០**-*ឯកឧត្តម* | **អាយ ខន** | *សមាជិកបំរុង* |
| **១១**-*ឯកឧត្តម* | **នាថ ស៊ីថុង** | *សមាជិកបំរុង* |
| **១២**-*ឯកឧត្តម* | **មឹន ស៊ាន** | *សមាជិកបំរុង* |
| **១៣**-*ឯកឧត្តម* | **ស៊ឹម សូលី** | *សមាជិកបំរុង* |
| **១៤**-*លោកជំទាវ* | **គ្រួច សំអាន** | *សមាជិកាបំរុង* |

# គណៈកម្មការពិសេសចំពោះកិច្ច
# ដើម្បីធ្វើវិសោធនកម្ម មាត្រា ៨៨ និងមាត្រា ១១១ថ្មី
# នៃរដ្ឋធម្មនុញ្ញ និងប្រការ ៤៧ថ្មី នៃបទបញ្ជាផ្ទៃក្នុង
# នៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

| | | |
|---|---|---|
| **១**-*ឯកឧត្តម* | **ឈួន ញ៉ិល** | *ប្រធាន* |
| **២**-*ឯកឧត្តម* | **ម៉ោញ សារផាន** | *អនុប្រធាន* |
| **៣**-*ឯកឧត្តម* | **ឯក សំអុល** | *អ្នករាយការណ៍* |
| **៤**-*ឯកឧត្តម* | **ជាម យៀប** | *សមាជិក* |
| **៥**-*ឯកឧត្តម* | **នាង ស៊ីថុង** | *សមាជិក* |
| **៦**-*ឯកឧត្តម* | **ហុង សុខហៀង** | *សមាជិក* |
| **៧**-*ឯកឧត្តម* | **ប៉ែន បញ្ញា** | *សមាជិក* |

## សំគាល់

**១**-អត្ថបទបទបញ្ញាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានអនុម័ត នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៣ នាសម័យប្រជុំរដ្ឋសភា លើកទី១ នីតិកាលទី១ ។

**២**-វិសោធនកម្មលើប្រការ ២៩ ប្រការ ៣១ និងប្រការ ៤៧ នៃបទ បញ្ញាផ្ទៃក្នុងនៃ រដ្ឋសភា ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ១៩៩៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៥ នីតិកាលទី ១ ។

**៣**-វិសោធនកម្មប្រការ ៣៦ និងប្រការ ៣៨ នៃបទបញ្ញាផ្ទៃក្នុង នៃរដ្ឋសភាត្រូវបាន រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៣ នាសម័យ ប្រជុំរដ្ឋសភាលើកទី ៩ នីតិកាលទី ២ ។

**៤**-វិសោធនកម្មប្រការ ២ ៣ ៤ ៥ ៦ ៧ ៩ ១០ ១៤ ១៥ ១៧ ២២ ៣១ថ្មី ៣៣ ៤០ ៤១ ៤៨ ៥១ ៥៥ ៥៦ ៥៨ ៥៩ ៦០ និងប្រការ៨៣ នៃបទ បញ្ញាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះ រាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភានៃ ព្រះរាជាណាចក្រកម្ពុជាអនុម័តនៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៥ នាសម័យ ប្រជុំរដ្ឋសភាលើកទី ២ នីតិកាលទី ៣ ។

**៥**-វិសោធនកម្មប្រការ ៤៧ថ្មី នៃបទបញ្ញាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រ កម្ពុជាត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា

*អនុម័តនៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៥ នាសម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភា នីតិកាលទី ៣ ។*

**៦**-*វិសោធនកម្មប្រការ ២ថ្មី ៥ថ្មី ១០ថ្មី ៣៥ ៤៧ថ្មី(ពីរ) និងប្រការ ៨២ នៃបទបញ្ជា ផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជាត្រូវបាន រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភលើកទី ៤ នីតិកាលទី៣ ។*

**៧**-*វិសោធនកម្មប្រការ ១៥ថ្មី និងប្រការ ៤៨ថ្មី នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃ ព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភានៃព្រះរាជាណា-ចក្រកម្ពុជាអនុម័តនៅថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ ។*

**៨**-*វិសោធនកម្មប្រការ ៦ថ្មី នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជ-ណាចក្រកម្ពុជា ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័តនៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ២០១៤ នាសម័យប្រជុំ រដ្ឋសភាជាវិសាមញ្ញ នីតិកាលទី ៥ ។*

**៩**-*វិសោធនកម្ម ជំពូកទី ១២ ថ្មី ប្រការ ៤៨ ថ្មី (ពីរ) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជណាចក្រកម្ពុជា ត្រូវបាន រដ្ឋសភានៃព្រះរាជា-ណាចក្រ កម្ពុជា អនុម័តនៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី៥។*

**១០**-*វិសោធនកម្មប្រការ ៣ថ្មី ប្រការ ៧ថ្មី ប្រការ ៨ ប្រការ ១០ថ្មី (ពីរ) ប្រការ ១៤ថ្មី ប្រការ ១៨ ប្រការ ២០ ប្រការ ២១ ប្រការ ២២ថ្មី ប្រការ ៣១ថ្មី(ពីរ) ប្រការ ៣៣ថ្មី ប្រការ ៣៤ ប្រការ ៣៦ថ្មី ប្រការ ៣៨ថ្មី ប្រការ ៤០ថ្មី និងប្រការ ៤៧ថ្មី(បី) នៃបទបញ្ជាផ្ទៃក្នុង នៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័តនៅថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៥ នីតិកាលទី ៥។*

**១១**-*វិសោធនកម្ម ជំពូកទី ១២ ថ្មី ប្រការ ៤៨ ថ្មី (បី) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជណាចក្រកម្ពុជា ត្រូវបាន រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៥។*